មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ទំនាស់ដីធ្លីរវាងតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា និង អ្នកភូមិ នៅ ឃុំថ្មដា ខេត្តពោធិ៍សាត់

## កម្រងប្រវត្តិករណី & បច្ចុប្បន្នភាព ខែតុលា ឆ្នាំ២០១៩

## ទិដ្ឋភាពទូទៅ

កម្រងករណីសិក្សានេះទាក់ទងនឹងទំនាស់ដីធ្លីរវាងអ្នកភូមិ នៅក្នុងឃុំថ្មដា និងតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា ខូ.អិល.ធី.ឌី នៅលើផ្ទៃដីនៃគម្រោងតំបន់សេដ្ឋកិច្ចពិសេសដើម្បីសម្រួលដល់ពាណិជ្ជកម្មជាមួយនឹងប្រទេសថៃ នៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ទំនាស់នេះបានចាប់ផ្តើមតាំងពី ខែវិច្ឆិកា ឆ្នាំ២០១០ ក្នុងខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា ដែលមានដំណើរការលើសកម្មភាពរួមមានទីផ្សារនាំចេញ/នាំចូល ដើម្បីផ្លាស់ប្តូរទំនិញ ឃ្លាំងសម្រាប់ផលិតផលកសិកម្ម កាសីុណូ ក្លឹបវាយកូនហ្គោល ក្លឹបហាត់ប្រាណ ចំណតយានយន្ត និងស្ថានីយ៍ប្រេងឥន្ធនៈ នៅលើផ្ទៃដីសរុបចំនួន ២.២៦៥ហិកតា។[1] តំបន់សេដ្ឋ កិច្ចពេសេសនេះត្រូវបានផ្តល់ឱ្យក្រុមហ៊ុន អឹម.ឌី.អេស ថ្មដា ខូ.អិល.ធី.ឌី («អឹម.ឌី.អេស») ជាក្រុមហ៊ុនកម្ពុជាដែលនាយកក្រុមហ៊ុន ឈ្មោះឧកញ៉ា ទ្រី ភាព។[2]

នៅក្នុងខែតុលា ឆ្នាំ២០១០ មុនពេលដែលតំបន់សេដ្ឋកិច្ចពិសេសទទួលបានការអនុញ្ញាត ក្រុមហ៊ុន អឹម.ឌី.អេស បានចាប់ផ្តើមឈូសឆាយដីដោយបានបំផ្លាញផ្ទះ និងទ្រព្យសម្បត្តិ និងឈូសឆាយលុបដីស្រែចំការផងដែរ។ ការឈូសឆាយបានបន្តរហូតដល់ឆ្នាំ២០១៤ ទោះបីជាមានការខិតខំប្រឹងប្រែងពីសហគមន៍ដើម្បីស្វែងរកដំណោះស្រាយក៏ដោយ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ កងកម្លាំងចម្រុះបានឈូសឆាយ និងកម្ទេចផ្ទះ និងផលដំណាំរបស់ប្រជាពលរដ្ឋចំនួន១១ គ្រួសារ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

ជាសរុប **មានគ្រួសារយ៉ាងហោចណាស់ ៩៧គ្រួសារ មកពីភូមិចំនួនបីផ្សេងៗគ្នាដែលទទួលរងផលប៉ះពាល់ពីទំនាស់ដីធ្លីនេះ។**[3] ដើម្បីបន្តការរស់នៅ ប្រជាពលរដ្ឋទាំងនោះជាច្រើនបានជំពាក់បំណុលគេ និងមួយចំនួនទៀតបានលក់ទ្រព្យសម្បត្តិ ឬធ្វើចំណាកស្រុក។ រហូតមកដល់បច្ចុប្បន្ននេះ **មានប្រជាពលរដ្ឋចំនួន ១៥គ្រួសារ ដែលកំពុងស្វែងរកដំណោះស្រាយ។**

[1] ទីស្តីការគណៈរដ្ឋមន្ត្រី សជណ លេខ ១៣៣៤ ថ្ងៃទី១៩ ខែវិច្ឆិកា ២០១០. http://business.sithi.org/upload/ressource/1540440637_kh.pdf

[2] ទីស្តីការគណៈរដ្ឋមន្ត្រី សជណ លេខ ១៣៣៤ ដែលទីស្តីការគណៈរដ្ឋមន្ត្រីអនុម័តលើការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ចុះថ្ងៃទី១៩ ខែវិច្ឆិកា ២០១០ http://business.sithi.org/upload/ressource/1540440637_kh.pdf ទោះបីជាយ៉ាងណាក៏ដោយ យោងឯកសារផ្លូវការ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ សូមមើល "ច្បាប់ និង បទប្បញ្ញត្តិ ដែលទាក់ទងនឹងការបង្កើត និងគ្រប់គ្រង់តំបន់សេដ្ឋកិច្ចពិសេស" ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ ឆ្នាំ២០១៣ ទំព័រទី២,ចូល២៣, https://bit.ly/2mkhCLO All-Regulations-related-to-SEZ-KH.pdf

[3] ភូមិសង្គមថ្មី ភូមិកណ្តាល និងភូមិឯកភាព សូមមើលក្នុង "របាយការណ៍សង្ខេបស្តីពីផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ ក្រុមហ៊ុន អិម.ឌី.អេសស្ថិតក្នុង ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់" របាយការណ៍រួម អង្គការនៃវេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្ស អង្គការមជ្ឈមណ្ឌលអប់រំច្បាប់ដើម្បីសហគមន៍ អាដហុក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លីកាដូ ខេត្តពោធិ៍សាត់ ថ្ងៃទី១៩ មេសា ២០១៧ ទំព័រ ២-៤ (អាចស្វែងរកបានជាឯកសារបោះពុម្ពពី អង្គការនៃវេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា)

## តំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា

នាយកក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស ថ្មដា ខូ.អិល.ធី.ឌី គឺជាឧកញ៉ាជនជាតិខ្មែរឈ្មោះលោក ទ្រី ភាព ដែលមានក្រុមហ៊ុនយ៉ាងហោចចំនួន ២២ នៅកម្ពុជា[4]។ ក្រុមហ៊ុននេះក៏មានសម្បទានដីសេដ្ឋកិច្ចចំនួន ២នៅក្នុងតំបន់តែមួយនេះដែលមានផ្ទៃដីសរុបចំនួន ៦.៣៥២ហិកតា។[5] អឹម.ឌី.អេស គឺក្រុមហ៊ុនមួយរបស់ក្រុមហ៊ុន ទ្រី ភាព គ្រុប ខូ.អិល.ធី.ឌី («ទ្រី ភាព គ្រុប»)[6] គឺជា ក្រុមហ៊ុនកម្ពុជាដ៏ធំមួយដែលមានដំណើរការលើសកម្មភាពអាជីវកម្មជាច្រើនរួមមានកសិឧស្សាហកម្ម ទេសចរណ៍ អាជីវកម្មសណ្ឋាគារ សិប្បកម្ម ផែស្ងួត តំបន់សេដ្ឋកិច្ចពិសេស និងចែកចាយប្រេងឥន្ធនៈ។[7] ក្រុមហ៊ុននេះតែងតែរងការចោទប្រកាន់ថាបានរំលោភសិទ្ធិមនុស្សនៅប្រទេសកម្ពុជា[8] ប៉ុន្តែត្រូវបានបដិសេធដោយក្រុមហ៊ុន។

នៅក្នុងឆ្នាំ ២០១៨ ក្រុមហ៊ុន អឹម.ឌី.អេស បានចាប់ដៃគូជាមួយក្រុមហ៊ុនចិនមួយឈ្មោះ ហេងហ៊ី ដើម្បីអភិវឌ្ឍតំបន់សេដ្ឋកិច្ចនេះ។




[4] ការចុះបញ្ជីពាណិជ្ជកម្មកម្ពុជា អិម.ឌី.អេស ថ្មដា អេសអ៊ីហ្សិត យូអិលធីឌី http://business.sithi.org/upload/press_release/1540458177_kh.pdf ទទួលបាននៅថ្ងៃទី១៨ ខែកញ្ញា ២០១៨ https://www.businessregistration.moc.gov.kh/ "សេវាកម្មអនឡាញ" "ស្វែងរក" វាយបញ្ចូលឈ្មោះ អិម.ឌី.អេស; ការចុះបញ្ជី: ផ្សេងៗ; គេហទំព័រផ្លូវការ ទ្រី ភាព គ្រុប "តំបន់សេដ្ឋកិច្ចពិសេស", ទ្រី ភាព គ្រុប យូអីលធីឌី,២០១៨ http://trypheapgroup.com/en/?page=10 អង្គការ Open Corporate ឧកញ៉ា ទ្រី ភាព ស្ថិតក្នុងតារាងជាអគ្គនាយក ឬជាប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងក្រុមហ៊ុនចំនួន ២២ https://opencorporates.com/officers?q=Try+PHEAP.

[5] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "កំណត់ត្រាសង្ខេបស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស ស្ដីពីការ «ទប់ស្កាត់ ការកាត់បន្ថយ និងការដោះស្រាយការរំលោភសិទ្ធិនានាពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជា៖ ចំណុចកែលម្អទាំងប្រាំពីរយ៉ាង" ទំព័រទី១៣ https://cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=83&id=5&lang=khm សូមមើលផងដែរក្នុងមូលន័យសង្ខេប https://cchrcambodia.org/admin/media/analysis/analysis/khmer/20181219%20Executive%20Summary_KHM-Final.pdf សូមមើលព័ត៌មានអំពីការវិនិយោគនិងព័ត៌មានរបស់សាលាក្រុង និងខេត្ត "ខេត្តពោធិ៍សាត់" ក្រុមបឹក្សាអភិវឌ្ឍកម្ពុជា, ខែមីនា ២០១៤, ទំព័រ ១១៣, http://www.cambodiainvestment.gov.kh/wp-content/uploads/2014/03/Pursat-Province_eng.pdf និង ការចុះបញ្ជីពាណិជ្ជកម្មកម្ពុជា អិម.ឌី.អេស អ៊ីមផត អ៊ិចផត យូអិលធីឌី ព័ត៌មានទូទៅ http://business.sithi.org/upload/press_release/1540458304_kh.pdf និងអគ្គនាយក http://business.sithi.org/upload/press_release/1540458677_kh.pdf ទទួលបាននៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៨ https://www.businessregistration.moc.gov.kh/.

[6] គេហទំព័រផ្លូវការ ទ្រី ភាព គ្រុប "តំបន់សេដ្ឋកិច្ចពិសេស", ទ្រី ភាព គ្រុប យូអិលធីឌី ២០១៨ http://trypheapgroup.com/?page=10

[7] គេហទំព័រផ្លូវការ ទ្រី ភាព គ្រុប "អាជីវកម្មរបស់យើង" http://trypheapgroup.com/?page=6#

[8] សំរាប់ព័ត៌មានបន្ថែមសូមមើល"ថ្លៃប្រណិត"ក្លូបូលវីតណេសថ្ងៃទី៦ខែកុម្ភៈឆ្នាំ២០១៥ https://www.globalwitness.org/en/campaigns/forests/cost-of-luxury/ ការកាប់ឈើយ៉ាងគគឹកគគ្រេង ភ្នំពេញប៉ុស្តិ៍ ២៩ តុលា ២០១៣ https://www.phnompenhpost.com/national/logging-mogul-blasted; "របាយការណ៍កោះហៅឧកញ៉ា ទ្រី ភាព ភ្នំពេញប៉ុស្តិ៍" ក្រុមកិច្ចការពិសេសសិទ្ធិមនុស្ស, ២៣ ធ្នូ ២០១៣ http://chrtf.blogspot.com/2013/12/report-calls-out-try-pheap-by-phnom.html "នរណាខ្លះទទួលបានផលពីការស្លាប់នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា?" ក្លូបលវីតណេស ថ្ងៃទី២០ កក្កដា ឆ្នាំ២០១៨ https://www.globalwitness.org/en/campaigns/cambodia/who-profits-death-cambodias-democracy/ ក្រុមហ៊ុន អិម.ឌី.អេស បដិសេធជាផ្លូវការរាល់ការរំលោភបំពានឬការប្រព្រឹត្តមិនត្រឹមត្រូវណាមួយជាលក្ខណៈប្រព័ន្ធ សូមមើលជាឧទាហរណ៍ ការកាប់ឈើយ៉ាងគគឹកគគ្រេង ភ្នំពេញប៉ុស្តិ៍ ២៩ តុលា ២០១៣ https://www.phnompenhpost.com/national/logging-mogul-blasted.

គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ រកមិនទាន់ឃើញប្រភពណាមួយបញ្ជាក់ថាក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មកម្ពុជានោះឡើយទេ។[9]

## ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

ក្នុងខែឧសភា ឆ្នាំ២០១៨ អាជ្ញាធរសាធារណៈបានប្រាប់ ម.ស.ម.ក ថា តំបន់សេដ្ឋកិច្ចពិសេសនោះត្រូវបានធ្វើរួចរាល់ ៦០-៧០% ហើយ និងថា ប៉ុស្តិ៍/ច្រកទ្វាររដ្ឋបាលនឹងត្រូវបង្កើតឡើងនៅព្រំប្រទល់កម្ពុជា/ថៃ ដើម្បីសម្រួលដល់ពាណិជ្ជកម្មផលិតផលកសិកម្មដោយប្រើប្រាស់បរិវេណនាំចេញ/នាំចូលនៃតំបន់សេដ្ឋកិច្ចពិសេស អឹម.ឌី.អេស។ ពួកគេបានបន្ថែមទៀតថា នៅពេលដែលផ្លូវធ្វើដំណើរពីក្រុងពោធិ៍សាត់ទៅឃុំថ្មដា ដែលបច្ចុប្បន្នកំពុងសាងសង់ត្រូវបានបញ្ចប់នោះ ដំណើរការអភិវឌ្ឍរបស់តំបន់សេដ្ឋកិច្ចពិសេសនឹងមានសន្ទុះកើនឡើង។

កាលពីខែសីហា ឆ្នាំ២០១៨ គ្រឿងចក្រសម្រាប់ឈូសឆាយរបស់ អឹម.ឌី.អេស អមដោយកម្លាំងទាហាន និងអាជ្ញាធរមូលដ្ឋានផងនោះត្រូវបានគេឃើញនៅក្នុងដីទំនាស់ ហើយការសាងសង់បានចាប់ផ្ដើមបន្តនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសតាំងពីពេលនោះមក។ គិតត្រឹមខែឧសភា ឆ្នាំ២០១៩ មានអគារជាច្រើនត្រូវបានសាងសង់រួចរាល់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះផងដែរ។ មានស្លាកយីហោដែលសរសេរជាអក្សរចិនជាច្រើនត្រូវបានដាក់តាំងនៅហាង និងអគារនានា និងមានកម្មករជាជនជាតិចិនជាច្រើនកំពុងមានវត្តមាននៅទីនោះ។




សំណង់កំពុងសាងសង់នៅតំបន់សេដ្ឋកិច្ចពិសេសថ្មដា




សំណង់ភោជនីយដ្ឋាននៅតំបន់សេដ្ឋកិច្ចពិសេសថ្មដា




សំណង់កាស៊ីណូកំពុងសាងសង់នៅតំបន់សេដ្ឋកិច្ចពិសេសថ្មដា

[9] https://www.businessregistration.moc.gov.kh/ សេវាកម្មអនឡាញ,ស្វែងរកពាក្យ "ហេងហ៊ី"

ក្នុងខែកក្កដា ឆ្នាំ២០១៩ អត្ថបទកាសែតមួយមានរាយការណ៍ថា ក្រុមអ្នកវិនិយោគជនជាតិចិនទាំងនោះមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង «អ្នកមានអំណាចម្នាក់នៅរាជធានីភ្នំពេញ» និងបានវិនិយោគជាទឹកប្រាក់ចំនួនជាង ៣២៣.៥៩៧ ដុល្លាសហរដ្ឋអាមេរិកដើម្បី «អភិវឌ្ឍទីក្រុងថ្មីមួយ» នៅក្នុងឃុំថ្មដា។[10] ខុនដូ ជាង ១០.០០០ បន្ទប់ រួមជាមួយនឹងសណ្ឋាគារប្រណិតៗលំដាប់ផ្កាយ ភោជនីយដ្ឋាន និងកាស៊ីណូលំដាប់ខ្ពស់ជាច្រើននឹងរំពឹងថាត្រូវសាងសង់ឡើងរួចរាល់ក្នុងរយៈពេល ៣-៥ ឆ្នាំខាងមុខនេះ។ មានសេចក្តីរាយការណ៍ថា រហូតមកដល់បច្ចុប្បន្ននេះមានទឹកប្រាក់សរុបចំនួន ៩៧.០៦៨.៤៧២ ដុល្លាសហរដ្ឋអាមេរិក ត្រូវបានចំណាយទៅលើគម្រោងសាងសង់ជាច្រើននៅក្នុងតំបន់ថ្មដា និងមានជនជាតិចិន «ជាច្រើនពាន់នាក់» កំពុងធ្វើការនិងរស់នៅទីនោះ។ ផ្លូវតភ្ជាប់ពីប្រទេសថៃមកខេត្តបាត់ដំបង ពោធិ៍សាត់ និងកោះកុង ត្រូវបានរាយការណ៍ផងដែរថាកំពុងតែដំណើរការហើយ។

## បញ្ហាគន្លឹះ

តាមរយៈការស្រាវជ្រាវរបស់ ម.ស.ម.ក ដោយសម្ភាសន៍ជាមួយសហគមន៍ដែលរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការទៅលើករណីនេះ ការឃ្លាំមើលករណីផ្ទាល់ និងការស្រាវជ្រាវបានបង្ហាញថា៖[11]

- **សិទ្ធិមានកម្មសិទ្ធិរបស់គ្រួសារទាំងនោះមិនត្រូវបានត្រួតពិនិត្យបញ្ជាក់ឱ្យបានត្រឹមត្រូវឡើយ**។ នៅក្នុងឆ្នាំ ១៩៩៩/២០០០ អ្នកភូមិដែលរងផលប៉ះពាល់ជាច្រើនបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដី ទាក់ទងនឹងដីបច្ចុប្បន្នឋិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទោះជាយ៉ាងណា ពួកគេនៅមិនទាន់បានទទួលបានចម្លើយពីអាជ្ញាធរនៅឡើយទេ។
- **ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហាក់ដូចជាមិនត្រូវបានអនុវត្ត** នៅមុនពេលចាប់ផ្តើមប្រតិបត្តិការ ហើយឯកសារនានាទាក់ទងនឹងតំបន់សេដ្ឋកិច្ចពិសេស និងការអភិវឌ្ឍ ក៏មិនមានផ្សាយជាសាធារណៈផងឡើយ។
- ក្នុងឆ្នាំ២០១៤ ក្រុមហ៊ុន អឹម.ឌី.អេស បានរុះរើកម្ទេចផ្ទះនិងផលដំណាំរបស់អ្នកភូមិចំនួន ១១គ្រួសារ ដោយមានវត្តមានកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្តនៅទីនោះផងដែរ។ ជាលទ្ធផល **ប្រជាពលរដ្ឋទាំងនោះត្រូវបានបណ្តេញចេញដោយបង្ខំពីដីរបស់ពួកគាត់**។ សហគមន៍ដែលរងផលប៉ះពាល់មិនត្រូវបាន**ពិគ្រោះយោបល់ដោយសមរម្យនោះទេ**។ ពុំមានការពិគ្រោះយោបល់ធ្វើឡើង មុនពេលដីរបស់ពួកគេត្រូវបានឈូសឆាយកាលពីឆ្នាំ២០១៤ នោះឡើយ។ ក្នុងខណៈដែលអាជ្ញាធរបានរាយការណ៍ថាមានកិច្ចប្រជុំជាច្រើនជាមួយសហគមន៍រងផលប៉ះពាល់នៅឆ្នាំ២០១០ ពួកគាត់ក៏បានទទួលស្គាល់ផងដែរថា ពុំមានការព្រមព្រៀងណាមួយបានកើតឡើងទេ។
- មានសេចក្តីរាយការណ៍ថា មានអ្នកភូមិជាច្រើនត្រូវបាន**គំរាមកំហែងពីសំណាក់អាជ្ញាធរ និង/ឬ តំណាងក្រុមហ៊ុន អឹម.ឌី.អេស** ក្នុងខណៈដែលពួកគាត់ប៉ុនប៉ងតវ៉ាទៅនឹងការរំលោភលើសិទ្ធិដីធ្លីរបស់ពួកគាត់។ ឧទាហរណ៍ជាក់ស្តែង ពួកគាត់ពិតជាបានរងការគំរាមកំហែងដោយការចាប់ខ្លួនក្នុងខណៈ ដែលកំពុងតវ៉ាទៅនឹងការឈូសឆាយរបស់ក្រុមហ៊ុន អឹម.ឌី.អេស ទៅលើដីធ្លីរបស់ពួកគាត់។

[10] ការផ្ទុះគ្រាប់បែកនៅតាមព្រំដែន″ បាងកកប៉ុស្ដិ៍ ១ កក្កដា ២០១៩ https://www.bangkokpost.com/thailand/general/1704672/boom-along-the-border

[11] លទ្ធផលការស្រាវជ្រាវដែលបានចេញផ្សាយ ក្នុងកំណត់ត្រាសង្ខេប ស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ″ទប់ស្កាត់ ការកាត់បន្ថយ និងការដោះស្រាយការរំលោភសិទ្ធិនានាពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជា៖ ចំណុចកែលម្អទាំងប្រាំពីរយ៉ាង″ ចេញផ្សាយក្នុងខែ ធ្នូ ឆ្នាំ២០១៨ អាចរកបាននៅគេហទំព័រមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា https://cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=83&id=5&lang=khm សូមមើលផងដែរក្នុងមូលន័យសង្ខេប https://cchrcambodia.org/admin/media/analysis/analysis/khmer/20181219%20Executive%20Summary_KHM-Final.pdf

- ទោះបីជាទំនាស់ដីធ្លីនេះបានកើតឡើងតាំងពីឆ្នាំ២០១០ ក៏នៅមានគ្រួសារចំនួន១៥ ដែលដីរបស់ពួកគាត់ឋិតនៅចំកណ្តាលនៃតំបន់សេដ្ឋកិច្ចពិសេស (នៅជិតកាស៊ីណូ) **កំពុងរង់ចាំដំណោះស្រាយនៅឡើយ។**

## បច្ចុប្បន្នភាពអំពីដំណើរការដោះស្រាយទំនាស់

**ខែឧសភា ឆ្នាំ២០១៧៖** មានសមាជិកសហគមន៍មួយចំនួនបានអះអាងថាពួកគាត់ត្រូវបានបង្ខំឱ្យទទួលយកសម្បទានដីសង្គមកិច្ច។

**ខែឧសភា ឆ្នាំ២០១៨៖** អាជ្ញាធរបានប្រាប់ ម.ស.ម.ក ថាពួកគេនឹងពន្លឿនដំណើរការដោះស្រាយទំនាស់ដើម្បីធានាថាដំណើរការដោះស្រាយទាំងមូលនឹងប្រព្រឹត្តទៅដោយគ្មានការរំខាន។ ក្នុងពេលជាមួយគ្នានេះដែរ តំណាងសហគមន៍ក៏បានរាយការណ៍ថា អាជ្ញាធរបានប្រាប់ពួកគាត់ថា ប្រសិនបើពួកគាត់មិនព្រមទទួលយកសម្បទានដីសង្គមកិច្ចនោះទេ ពួកគាត់នឹងមិនបានទទួលដំណោះស្រាយអ្វីផ្សេងទៀតក្រៅពីនេះឡើយ។

**ខែឧសភា ឆ្នាំ២០១៩៖** អាជ្ញាធរបានប្រាប់ ម.ស.ម.ក ថាពួកគេបានរៀបចំដីទុកដែលមានក្បាលដីទំហំ (០,៥ ហិកតា) ក្នុងមួយគ្រួសារជាសម្បទានដីសង្គមកិច្ចនៅជាប់នឹងតំបន់សេដ្ឋកិច្ចពិសេស។ អាជ្ញាធរផ្សេងទៀតបានប្រាប់ ម.ស.ម.ក ដីដែលបានរៀបចំទុកនោះពុំមែនជាសម្បទានដីសង្គមកិច្ចទេ ប៉ុន្តែជាដីដោះដូរ និងថាទោះបីជាមធ្យមានទំហំ ០,៥ ហិក តា ប៉ុន្តែការកំណត់ទំហំដីអាចនឹងពិចារណាទៅតាមស្ថានភាពជាក់ស្តែង។ ប្រសិនបើការលើកឡើងពិតជាដូច្នេះមែន មានន័យថា គ្រួសារដែលទទួលបានដីដោះដូរនោះ នឹងអាចទទួលបានប័ណ្ណកម្មសិទ្ធិដី ហើយពួកគេក៏អាចនឹងលក់ដីនោះបានតាមក្តីប្រាថ្នារបស់គេដែរ។

**ខែឧសភា ឆ្នាំ២០១៩៖** អាជ្ញាធរបានប្រាប់ ម.ស.ម.ក ថា សម្បទានដីសង្គមកិច្ច/ដីដោះដូរ កំពុងត្រូវបានប្រតិបត្តិការបោសសំអាតមីន និងគ្រាប់មិនទាន់ផ្ទុះ ហើយនឹងអាចបង្ហាញបាននៅពេលណាដែលការងារនេះត្រូវបានបញ្ចប់។

### អ្នកដែលយល់ព្រមទទួលយកសម្បទានដីសង្គមកិច្ច/ដីដោះដូរ នៅមិនទាន់បានចូលកាន់កាប់ដីនោះនៅឡើយទេ

- គ្រួសារដែលយល់ព្រមទទួលយកសម្បទានដីសង្គមកិច្ច/ដីដោះដូរ បានទទួលសលាកបត្រព័ត៌មានហើយ ប៉ុន្តែពួកគេនៅតែមិនទាន់អាចចូលទៅកាន់កាប់ដីបានដោយសារតែនៅមានគ្រាប់មីនមិនទាន់ផ្ទុះជាច្រើននៅទីនោះ។ គ្រួសារទាំងនោះក៏នៅតែមិនទាន់បានដឹងថាដីដែលគេនឹងទទួលបាននោះនៅទីណានៅឡើយ ហើយក៏មានសេចក្តីរាយការណ៍ថា អាជ្ញាធរមិនទាន់អនុញ្ញាតឱ្យពួកគេចូលទៅកាន់កាប់ដីនៅតំបន់នោះឡើយ។ ហើយក៏មានព័ត៌មានផងដែរថា ផ្នែកខ្លះនៃសម្បទានដីសង្គមកិច្ច/ដីដោះដូរ កំពុងត្រូវបានមេបញ្ជាការទាហានម្នាក់ទាមទារមកកាន់កាប់ផងដែរ។

### ប្រជាពលរដ្ឋចំនួន១៥ គ្រួសារ កំពុងរង់ចាំដំណោះស្រាយនៅឡើយ

- អាជ្ញាធរនៅតែបន្តការអះអាងថា គ្រួសារទាំងនោះពុំមានឯកសារភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីភាពជាម្ចាស់លើដីដែលពួកគេកំពុងទាមទារនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះទេ។

- គ្រួសារជាច្រើនបានបាត់បង់ដីក្នុងចន្លោះពី ៣ ទៅ ៣៨ហិកតា ដែលមានទីតាំងស្ថិតនៅចំកណ្តាលបេះដូងនៃតំបន់សេដ្ឋកិច្ចពិសេស ដូច្នេះពួកគេពុំអាចទទួលយកដីដែលអាជ្ញាធរគ្រោងនឹងផ្តល់ឱ្យ ដែលមានទំហំតូចពេក-០,៥ហិកតា (៥០x១០០ម)តែប៉ុណ្ណោះ។

- **ខែមេសា ឆ្នាំ២០១៩៖** ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ បានជួបសហគមន៍ និងបាននិយាយថានឹងពិនិត្យមើលតម្លៃដីនៅទីនោះតាមតម្លៃទីផ្សារ ហើយបានប្រាប់សហគមន៍ផងដែរថា ពួកគេកំពុងធ្វើការលើករណីនោះជាមួយនាយករដ្ឋមន្ត្រី។

- **ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៩៖** ប្រជាពលរដ្ឋ១៥គ្រួសារបានដាក់ញត្តិទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ («ក្រសួងកសិកម្ម») ស្នើសុំពន្លឿនដំណើរការដោះស្រាយទំនាស់នេះ។

- **ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩៖** ប្រជាពលរដ្ឋ១៥គ្រួសារបានដាក់ញត្តិទៅរដ្ឋសភាជាតិនៅរាជធានីភ្នំពេញ ស្នើសុំឱ្យមានដំណោះស្រាយទំនាស់ដីធ្លីនេះ និងបានស្នើសុំប្រធានរដ្ឋសភាជាតិចាត់វិធានការរកដំណោះស្រាយឱ្យពួកគាត់។ ញត្តិនោះត្រូវបានទទួលយក ហើយតំណាង ៤នាក់ ត្រូវបានអនុញ្ញាតចូលជួបមន្ត្រីម្នាក់ដែលចុះហត្ថលេខាទទួលញត្តិរបស់ពួកគេ។

- **ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩៖** គ្រួសារទាំងនោះបានដាក់ញត្តិទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ («ក្រសួងរៀបចំដែនដី») និងក្រសួងមហាផ្ទៃ ប៉ុន្តែមានតែក្រសួងរៀបចំដែនដីមួយប៉ុណ្ណោះដែលយល់ព្រមទទួលញត្តិនោះ។ រីឯក្រសួងមហាផ្ទៃបានបដិសេធទទួលញត្តិ ដោយបញ្ជាក់ថាករណីនោះគឺនៅក្រោមយុត្តាធិការរបស់ក្រសួងរៀបចំដែនដី។

- **ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖** ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញលិខិតផ្លូវការមួយផ្ទេរការដោះស្រាយទំនាស់នេះទៅឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ លិខិតនោះគឺឆ្លើយតបទៅនឹងរបាយការណ៍របស់សមាជិកមួយនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យាបល់ ដែលធ្វើការលើទំនាស់ដីធ្លីនោះ និងមានចំណារពីនាយករដ្ឋមន្ត្រីផងដែរ។

- **ថ្ងៃទី៧-៨ ខែសីហា ឆ្នាំ២០១៩៖** ប្រជាពលរដ្ឋ១៥គ្រួសារបានប៉ុនប៉ងជួបអភិបាលខេត្តពោធិ៍សាត់ដើម្បីពិភាក្សាអំពីដំណោះស្រាយទំនាស់ដីធ្លីនោះ។ ដោយសារអវត្តមានរបស់អភិបាលខេត្ត ពួកគេបានជួបតែប្រធានមន្ទីររៀបចំដែនដីខេត្តប៉ុណ្ណោះ។

- **ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩៖** អនុវត្តតាមលិខិតចុះ ៣១ ខែកក្កដា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីបានចាត់តាំង ឯកឧត្តម យុន ហាំង ទេសរដ្ឋមន្ត្រី និងជាអនុប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីចុះពិនិត្យមើលករណីនេះ។ ឯកឧត្តមបានជួបប្រជាពលរដ្ឋទាំង ១៥គ្រួសារ និងបានប្រាប់ពួកគេថាឯកឧត្តមនឹងសិក្សាលើករណីនេះ និងរកឱ្យឃើញពីតម្រូវការរបស់ពួកគេ បន្ទាប់មកនឹងរាយការណ៍ទៅថ្នាក់លើដើម្បីស្វែងរកដំណោះស្រាយ និងបញ្ចប់ទំនាស់នេះ។

- **ថ្ងៃទី២១-២២ ខែសីហា ឆ្នាំ២០១៩៖** ក្រុមការងាររបស់អន្តរក្រសួងបានចុះទៅជួបប្រជាពលរដ្ឋរងផលប៉ះពាល់ និងបានដាក់ស្នើឡើងនូវដំណោះស្រាយបីចំណុចទៅប្រជាពលរដ្ឋដើម្បីជ្រើសរើស៖ ទី ១)យកដីដែលបាត់បង់មកវិញ ទី ២)ការបែងចែកដីនៅទីតាំងផ្សេងទៀតជាដីដោះដូរ និងទី ៣) ទទួលយកសំណងជាថវិកា។ ប្រជាពលរដ្ឋទាំង ១៥ គ្រួសារបានជ្រើសរើសយកដីដែលពួកគេបាត់បង់មកវិញ។ ក្រុមការងារបានប្រាប់គ្រួសារទាំងនោះថា ពួកគេនឹងរាយការណ៍ទៅថ្នាក់ជាតិដើម្បីពិចារណា។

- **ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩៖** ក្រសួងកសិកម្មបានចេញលិខិតជាផ្លូវការមួយឆ្លើយតបទៅនឹងញត្តិចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៩ របស់ប្រជាពលរដ្ឋទាំង ១៥គ្រួសារ ដោយបានបញ្ជាក់ថាទីតាំងរបស់ក្រុមហ៊ុនទាំងពីរ (អឹម.ឌី.

អេស ថ្មដា ខូ.អិល.ធី.ឌី និង អឹម.ឌី.អេស ហេងហ៊ី ថ្មដា) ដែលក្នុងលិខិតនោះបានពិពណ៌នាថាជាសម្បទានដីសេដ្ឋកិច្ច ជាជាងតំបន់សេដ្ឋកិច្ចពិសេស គឺមិនឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មទេ និងបានផ្តល់ជាអនុសាសន៍ថា ក្រុមអ្នកតវ៉ាគួរទាក់ទងទៅអាជ្ញាធរខេត្តឱ្យដោះស្រាយករណីនេះវិញ។

## អនុសាសន៍ចំពោះរាជរដ្ឋាភិបាលកម្ពុជា

ម.ស.ម.ក សូមអំពាវនាវទៅអាជ្ញាធរ៖

I. សូមធានាថា ដំណោះស្រាយដែលបានស្នើឡើងដោយប្រជាពលរដ្ឋទាំង ១៥គ្រួសារ ដែលកំពុងរង់ចាំដំណោះស្រាយត្រូវបានផ្តល់ជូនពួកគាត់ឱ្យទាន់ពេលវេលាអនុលោមទៅតាមបទដ្ឋានជាតិ និងអន្តរជាតិ។

II. ដំណើរការបោសសំអាតគ្រាប់មីន គួរធ្វើឱ្យបានឆាប់ ដើម្បីអនុញ្ញាតឱ្យគ្រួសារដែលយល់ព្រមទទួលយកសម្បទានដីសង្គមកិច្ច/ដីដោះដូរ រួចហើយអាចចូលទៅតាំងទីលំនៅនៅទីតាំងនោះបាន។

III. សូមធានាថា សម្បទានដីសង្គមកិច្ច/ដីដោះដូរ ផ្សារភ្ជាប់ដោយហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងអស់សម្រាប់ប្រជាពលរដ្ឋដែលរស់នៅទីនោះ ដូចជាភ្លើងអគ្គិសនី ទឹកស្អាត និងគ្រឿងបរិក្ខាអនាម័យ ក៏ដូចជាសាលារៀន។

បញ្ហាភាគច្រើនដែលបានបង្ហាញនៅក្នុងកម្រងជីវប្រវត្តិនេះគួរត្រូវបានជៀសវាង ប្រសិនបើមានតម្រូវការជាមុនក្នុងការអនុវត្តសម្បទានដីសេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ចពិសេសផ្សេងទៀត ឱ្យមានប្រសិទ្ធភាព។ បើធ្វើបែបនេះបាននោះ នឹងជួយសន្សំពេលវេលា ថវិកា និងការខិតខំប្រឹងប្រែងសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ និងធ្វើឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ ដើម្បីឱ្យមានការទប់ស្កាត់ ការកាត់បន្ថយ និងដោះស្រាយការរំលោភសិទ្ធិមនុស្សដោយមានប្រសិទ្ធភាព ម.ស.ម.ក សូមជម្រុញឱ្យរាជរដ្ឋាភិបាលកម្ពុជា៖

I. តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមច្បាស់លាស់ មុនពេលអនុញ្ញាតឱ្យមានគម្រោងអភិវឌ្ឍន៍ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬតំបន់សេដ្ឋកិច្ចពិសេសណាមួយ និងធានាថារបកគំហើញនៃការវាយតម្លៃទាំងនេះត្រូវចែកចាយដល់សហគមន៍រងផលប៉ះពាល់ និងសាធារណៈជនឱ្យទាន់ពេលវេលា និងទាមទារឱ្យមានយន្តការតាមដាន ទៅលើការអនុវត្តដោយអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិរួមមានគោលការណ៍លេខ ១៨ នៃគោលការណ៍ណែនាំស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងបទដ្ឋានសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។

II. គិតគូឡើងវិញអំពីកិច្ចសន្យារបស់ក្រុមហ៊ុនប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស និងតម្រូវឱ្យក្រុមហ៊ុនណា ដែលមិនបានអនុវត្តហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីបង្កើតផែនការកាត់បន្ថយចំពោះហានិភ័យនានាដែលបានរកឃើញ និងតាមដានការអនុវត្តទាំងនោះ។ រាជរដ្ឋាភិបាលម្ពុជាគួរទាមទារឱ្យក្រុមហ៊ុនទាំងនោះផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្សណាមួយកើតឡើង។

III. ធានាថាឱ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍រងផលប៉ះពាល់ដោយសារទំនាស់ដីធ្លីមុនពេលផ្តល់កិច្ចសន្យាណាមួយ និងធានាថាពួកគាត់នៅតែបន្តចូលរួមការវាយតម្លៃអំពីការអភិវឌ្ឍនានា ព្រមទាំងធានាឱ្យគោរពតាមគោលការណ៍នៃការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញផងដែរ។

IV. ធានាអំពីការដោះស្រាយទំនាស់ដីធ្លីទាន់ពេលវេលា អនុលោមទៅតាមបទដ្ឋានអន្តរជាតិដូចជាមាត្រា ៣ (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងគោលការណ៍លេខ ២៦ នៃគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។

V. បញ្ឈប់រាល់ទម្រង់ការតាមដាន ការបៀតបៀន និងការដាក់ទណ្ឌកម្មលើអ្នកការពារសិទ្ធិមនុស្សពាក់ព័ន្ធនឹងទំនាស់ដីធ្លី។

VI. បង្កើតយន្តការដោះស្រាយទំនាស់ (យន្តការទទួលពាក្យបណ្តឹង) ឯករាជ្យ ឥតលម្អៀង និងមានប្រសិទ្ធភាពដើម្បីទទួលនិងដោះស្រាយបណ្តឹងរបស់កម្មករក្នុងតំបន់សេដ្ឋកិច្ចពិសេស និងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារតំបន់សេដ្ឋកិច្ចពិសេស។

VII. បង្កើតនិងអនុវត្តផែនការសកម្មភាពថ្នាក់ជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដោយប្រឹក្សាយោបល់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីផ្សព្វផ្សាយ និងអនុវត្ត គោលការណ៍ណែនាំស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។